# ការសំភាសន៍របស់លោកយាយ គឹម លន់ ហៅគឹម សំបូរ

កៈ អ្នកដែលសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍គឹម លន់

## ការសង្ខេបរបស់លោកយាយ គឹម លន់ ហៅគឹម សំបូរ

លោកយាយគឹម លន់ គាត់កើតនៅកំពង់សំណាញ់ហើយគាត់មានបងប្អូនប្រុសមួយនាក់ហើយកើតគាត់ទាំងពីរនាក់ជាកូនភ្លោះតែអកុសល្យអីបងប្អូនប្រុសគាត់ត្រូវបានស្លាប់នៅពីតូច ហើយម្តាយឪពុករបស់អ៊ំស្រីគឺស្រលាញ់គាត់ណាស់ ហើយពួកគាត់បានផ្លាស់ប្តូរទីលំនៅនៅខេត្តកោះកុង ដែលពេលនោះទឹមតែយកបានមកពីថៃវិញ។ គាត់បានធ្វើការនៅពេទ្យធំជាមួយឪពុកគាត់ដើម្បីចិញ្ចឹមជីវិត។ ហើយក្រុមគ្រួសារក៏ជាអ្នកធ្វើស្រែចំការដែរកាលពេលមិនទាន់ទៅកោះកុង ហើយធ្វើនៅតាកែវព្រោះឪពុកជាអ្នកតាកែវ។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកយាយដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់លោកយាយ នាងខ្ញុំឈ្មោះញ៉ែម សុគន្ធាជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់លោកយាយនៅក្នុងថ្ងៃនេះពួកយើងសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិព្រែកហូរខាងលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា ។ហើយពួកយើងសំភាសន៍នៅក្នុងខែមិនា ឆ្នាំ២០១៨ ហើយអីចឹងនាងខ្ញុំសូមចាប់ផ្តើមសំភាសន៍អំពីជីវប្រវត្តិរបស់លោកយាយមានដូចតទៅ!!អ៊ីចឹងលោកយាយសូមប្រាប់ឈ្មោះពេញហាំ ឈ្មោះលោកយយាមានឈ្មោះអីគេដែរ?

ខៈ ឈ្មោះញ៉ុមឈ្មោះ លន់ ហើយត្រកូលឈ្មោះគឹម !! គឹម លន់។

កៈ គឹម លន់ !!

ខៈចាំ!!

កៈ សំរាប់ឥឡូវលោកយាយអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ញ៉ុមអាយុន៧២ហើយ!!

កៈ ចា៎៧២ឆ្នាំហើយ?

ខៈចា៎!!

កៈ សំរាប់លោកយាយឆ្នាំខ្មែរកើតឆ្នាំសត្វអីគេវិញយាយ?

ខៈ ខ្ញុំ ខ្ញុំកើតឆ្នាំច ។

កៈ អ៊ីចឹងលោកយាយកើតឆ្នាំចហោ?

ខៈ ចា៎!!កើតឆ្នាំច។

កៈ កើតឆ្នាំច។

ខៈ ឆ្នាំច ខែ០៩ ខែភទ្របទហ្នឹង ខែភទ្របទខែភ្ជុំ។

កៈ ហ្វូ៎!!តែនៅក្នុងសំបុត្រកំនើតគេដាក់ខែឧសភាហ្នឹងលោកយាយ។

ខៈ ដឹងអីទេ ប្រហែលជាដាក់ខុសហើយមើលទៅ!!តែដាក់តាមគេម៉ងហ្នឹងទៅ!!

កៈ ចា៎!!ប៉ុន្តែលោកយាយប្រាប់ថ្ងៃខែឆ្នាំកំណើតខ្លួនឯងកើតនៅក្នុងថ្ងៃខែឆ្នាំណាចាំខ្លួនឯងហា៎!!

ខៈ ឆ្នាំច ហើយកើតខែ០៩!!

កៈ ខែ០៩ទេហោ?

ខៈចា៎!!

កៈ កញ្ញាទេហោ?

ខៈ មិនដឹងខែអីគេទេមីអូន!!

កៈ មករា កុម្ភៈ មិនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា !ត្រូវហើយខែកញ្ញា!!ភទ្របទហ្នឹងហើយខែភ្ជុំ?

ខៈ ហ្នឹងហើយខែភ្ជុំ។

កៈ អញ្ចឹងលោកយាយកើតចំពេលអាខែភ្ជុំហ្នឹងហោ?

ខៈ ចា៎!!

កៈ ចាំឆ្នាំខ្លួនឯងកើតទេ ឆ្នាំណាវិញ?

ខៈ អត់ចាំ មិនដឹង៨០ប៉ុន្មានទេកូន!!

កៈចា៎!!

ខៈ ឆ្នាំ១៩៤០ប៉ុន្តែមិនដឹង៤០ប៉ុន្មាន!!

កៈចា៎!

ខៈ អត់ចាំបានភ្លេចអស់ហើយ។

កៈ
ឥឡូវមិញលោកយាយថាកើតគឺកើតនៅក្នុងខែកញ្ញាប៉ុន្តែនៅក្នុងសំបុត្រកំនើតគេបញ្ជាក់ប្រាប់ថាលោកយាយឈ្មោះគឹម លន់ កើតនៅថ្ងៃសៅរ៍ទី១១ ខែឧសភា ឆ្នាំ១៩៤៩!!

ខៈចា៎!!

កៈ
ហ្នឹងហើយអញ្ចឹងអើរពិតឬក៏ក្លែងក្លាយញ៉ុមអត់ដឹងទេគ្រាន់តែញ៉ុមមើលនៅក្នុងសំបុត្រកំណើតប៉ុន្តែលោកយាយប្រាប់ថាលោកយាយអាយុប៉ុន្មានហើយ លោកយាយ៧៣ហោ?ខៈចា៎!!

កៈចា៎ហ្នឹងហើយអ៊ិចឹងបើសិនជា!!

ខៈ ចូលជិត៧៣ហើយ ប៉ុន្តែឥឡូវវាមិនទាន់ចូលឆ្នាំទេថាខ្ទង់៧២ចុះ!!

កៈ ចាំ!!ហ្នឹង អញ្ចឹងកូនចៅជំនាន់ក្រោយចង់ដឹងអីចឹងទៅអាចមើលតាលោកយាយវិញប្របហែលជាត្រូវជាងបើសិនជាយកតាមសំបុត្រកំនើតប្របហែលជាខុសទេ!!!

ខៈចាំ!!

កៈអញ្ចឹងលោកយាយកើតស្រុកកំណើតនៅឯណាវិញ?

ខៈ ញ៉ុមស្រុកនៅកំពង់សំណាញ់។

កៈ ចាំ!!អ៊ិចឹងនៅក្នុងសំបុត្រកំនើតរបស់លោកយាយគេដាក់នៅក្នុងភូមិកំពង់សំណាញ់ ឃុំតាខ្មៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា។

ខៈចាំ!!

កៈ ប៉ុន្តែឥឡូវអាភូមិអីវ៉ាន់ហ្នឹងគេដូរអស់រលីងហើយហ្នឹងយាយ!!

ខៈចាំចាំ!!

កៈ គេលែងដាក់ស្រុកកណ្តាលស្ទឹងហើយ!!

ខៈ គេលែងហៅកណ្តាលស្ទឹងហើយ!!

កៈ គេដូរមកក្រុងតាខ្មៅអីវ៉ាន់អស់រលីងហើយអស់ហើយហ្នឹង។

ខៈ ចាំហ្នឹងហើយ !!

កៈ លោកយាយសំរាប់លោកយាយក្រៅពីឈ្មោះលន់មានអ្នកណាគេដាក់ងារអីអោយផ្សេងទៀតទេ?

ខៈ អត់ផង!!

កៈ តែឈ្មោះមួយហ្នឹងមួយទេហី?

ខៈចាំ!!

កៈអត់មាននៅពីតូចម៉ែឪហៅផ្សេងអីទេហី?

ខៈ អត់ទេ។

កៈ តែមួយហ្នឹងគត់។

ខៈហ្ន៎ចាំ!! តែពេលកាលញ៉ុមធ្វើការដាក់ឈ្មោះផ្សេង។

កៈ ឈ្មោះអីគេវិញយាយ?

ខៈ ញ៉ុមកាលញ៉ុមធ្វើការជំនាន់សម្តេចសីហនុឈ្មោះនៅព្រោះអីអញ្ចេកពុកខ្ញុំនៅផ្លាស់ទៅគាត់ធ្វើការនៅពេទ្យធំដល់ពេលគេទាមទារយកខេត្តកោះកុងខេត្តព្រះវិហារបានគេអោយគាត់ទៅធ្វើការនៅណោះ ហើយមានប្រាក់ចាញ់ប្រាក់អីអញ្ចឹងហ្ន៎!!

កៈចាំ!!

ខៈ ហើយដល់ពេលញ៉ុមទៅតាមគាត់ទៅរៀននៅឯកោះកុងហ្នឹងដល់ពេលហើយញ៉ុមចូលធ្វើការនៅពេទ្យញ៉ុមដាក់ឈ្មោះបញ្ជីជាតិឪពុកម្តាយញ៉ុមដាក់ឈ្មោះមកដាក់ឈ្មោះគឹម សំបូរ!!

កៈចាំ!!

ខៈតែដល់មកឥឡូវនេះញ៉ុមដាក់គឹម លន់ គេហៅយាយលន់ យាយលន់ហ្នឹងក៏ដាក់គឹម លន់វិញទៅ។

កៈ ប៉ុន្តែឈ្មោះមែនទែនពិតប្រាកដអីគេ?

ខៈ មែនទែនពិតប្រាកដក្នុងបញ្ជីជាតិគឹម សំបូរ!!

កៈ គឹម សំបូរទេ!!

ខៈចាំ!!

កៈ អញ្ចឹងពីដើមដំបូងមកគឹម សំបូរទេ?

ខៈចាំ!!

កៈអញ្ចឹងទឹមចូលដល់គឹម លន់ ទឹមចូលពីសម័យឥឡូវហ្នឹងទេ?

ខៈ ទឹមដូរមកបែកអាពតហ្នឹងមកទេ!!

កៈ ហ្ហ៎!!

ខៈ ពីព្រោះអ្នកស្រុកជិតខាងគេជិះតែ បងប្អូនអីគេដឹងតែគឹម សំបូរអញ្ចឹងទៅណាស់!!

កៈចាំ!!

ខៈ ហើយដល់ពេលយើងធ្វើការម៉ែឪដាក់បញ្ជីជាតិគេអត់ស្គាល់ទេ គេស្គាល់តែលន់ លន់ទេហ្នឹងណាស់!!

កៈ អ្នកណាគេអ្នកហៅបង្កើតឈ្មោះហ្នឹងអោយយាយវិញ?

ខៈ ហ៊ីអោយជូនម៉ែញ៉ុមហ្នឹងហាំ!!

កៈ ចាំ!!ដូចរបៀបថាអោយជូយគ្នា!!

ខៈ អោយជូនគ្នា!!

កៈ អោយជូនគ្នាហេ!!អោយជូនឈ្មោះម៉ែ!!

ខៈចាំ!!

កៈម៉ែឈ្មោះប៊ុន កូនឈ្មោះលន់ អ៊ីចឹងទៅ?

ខៈចាំ!!

កៈនៅក្នុងសំបុត្រកំនើតនេះប្រាប់!!

ខៈចាំ!!

កៈលោកយាយមានបងប្អូនប្រុសស្រីប៉ុន្មាននាក់វិញ?

ខៈ ញ៉ុមអត់ម្នាក់ឯងគត់!!កើតទឹមតែចេះអង្គុយចេះអីស្លាប់អស់ទៅ!!!មានតែម្នាក់ឯងហ្នឹង!

កៈ តែពេលឥឡូវទោះគាត់តស្លាប់ហើយក៏ដោយតែប៉ុន្មាននាក់គាត់ស្លាប់ទៅហ្នឹង?

ខៈ អត់មាន!!

កៈ ចុះយាយមិញថាចេះអង្គុយចេះអីមិញអ្នកណាគេវិញ?

ខៈ ហ្នុំបងញ៉ុមហ្នឹងគេកើតមុនញ៉ុមហ្នឹងហាំ!!

កៈចាំ!!

ខៈជូនកាលគាត់ទឹមចេះអង្គុយ ដូចថាពោះធំអញ្ជឹងទៅគាត់អត់គង់អញ្ជឹងទៅណាស់!!

កៈចាំ!!

ខៈ ដល់ពេលគេបបួលគាត់មកសុំព្រះអង្គនៅទន្លេបាទីនេះ ប្រាសាទនាងខ្មៅហ្នុំ!!

កៈចាំ!

ខៈ
ដល់ពេលមកសុំទៅយប់ឡើងគេអោយយល់សព្វគាត់ថាគេអោយមនុស្សម្នាក់ដៃ៤ជើង៤ហើយគាត់ប្រកែកគាត់ថាគាត់អត់យកទេ
គាត់យកដៃ២ជើង២ដូចគេធម្មតាទេ!!ដល់ពេលកើតមកភ្លោះស្រីញ៉ុមប្រុសមួយស្រីមួយហ្នឹង!!
ហើយអាបងហ្នឹងចេះអង្គុយហ្នឹងកើតកញ្ច្រឹលហ្នឹងងាប់ទៅ។

កៈហ្នុំ!!

ខៈ នៅតែខ្ញុំម្នាក់ឯងទៅ!!

កៈអញ្ជឹងទៅសុំអីគេព្រះអង្គហ្នឹងទៅបានកូនភ្លោះ?

ខៈ បានកូនភ្លោះ។

កៈ តែអកុសលអីម្នាក់ប្រុសហ្នឹងស្លាប់បាត់ កើតកញ្ច្រឹលហ្នឹង!!

ខៈចាំ!!

កៈ ចេះអង្គុយហើយហោ?

ខៈ ចេះអង្គុយហើយ!!កៈហ្ហ៎!!ខៈ ហើយយើងពីដើមយើងដុតចង្កៀងប្រេងកាត អាប្រេងសាំងហ្ហ៎!! ដល់តែអស់អញ្ចឹងទៅឪពុកធំញ៉ុមហ្នឹងឃើញអាហ្នឹងវាកើតកញ្ច្រឹល គាត់បំបែកពីម្ដាយញ៉ុមហ្នឹងហា៎ គាត់បំបែក ផ្ទះនៅជិតគ្នាហ្នឹងហា៎!!គាត់យកទៅមើលមួយទៅ ព្រោះគាត់អត់កូនអត់ចៅអី ដល់ពេលអស់អាចង្កៀងប្រេងកាតហ្នឹង ហាអាអស់ប្រេងសាំងហ្នឹង អស់ទៅក៏គាត់បើកចាក់បើកចាក់ទៅវាឆាបហ្ហ៎!!
ឆាបឆេះអាផ្ទះហ្នឹងទៅគាត់ក៏ក្រវាត់អាប្រេងសាំងហ្នឹងមកខាងក្រៅទៅហើយឆេះផ្ទះជញ្ជាំងមួយចំហៀងហ្នឹងគាត់ក៏បីឆក់អាបងញ៉ុមហ្នឹងបីមកក្រៅហ្នឹងដូចថាវាធ្លាបងាប់ក្ដៅខ្លួនតែ២ ៣ថ្ងៃងាប់ទៅ អានិតគាត់ណាស់អញ្ចឹង!!

កៈ អញ្ចឹងចាំឈ្មោះបងរបស់យាយទេគាត់ទូចមួយហ្នឹង?

ខៈ គឹម សម្បត្តិ។

កៈ សម្បត្តិហោ?

ខៈចា៎!!

កៈ ហេឈ្មោះពិរោះទៀតហា៎!!ល្អទៀតហា៎ ហើយទៅកើតជំងឺកញ្ច្រឹលស្លាប់ទៅ!!

ខៈចា៎!!

កៈ
កុំអីបានភ្លោះមួយគូបាត់!!អ៊ំមានដឹងទេថាភ្លោះហ្នឹងមុខដូចគ្នាទេ?ពិតតែស្រីមួយប្រុសមួយមែន ប៉ុន្តែមុខដូចគ្នាអត់?

ខៈអត់បានសួរផង។

កៈ អត់ដែលសួរគាត់ផងហោ?

ខៈចា៎!!ឮសួរគាត់ថាស្លាប់ហ្នឹងហើៗម៉ងទៅ!!អត់សួរអត់នាំអី!!

កៈចា៎!!អញ្ចឹងស្លាប់ដោយសារមូលហេតុជំងឺកញ្ច្រឹល។

ខ៖ចាំ!!

ក៖ ហ្នឹងហើយ អ៊ិចឹងលោកយាយសំរាប់ម្ដាយរបស់លោកយាយហាគាត់ឈ្មោះអីគេដែរ?

ខ៖ ឈ្មោះអ៊ុយ ប៊ុន។

ក៖ អ៊ុយ ប៊ុន។ហ្នឹងហើយ លោកយាយចាំថាគាត់កើតឆ្នាំខ្មែរគាត់កើតឆ្នាំអីគេទេ?

ខ៖ អត់ចាំផងមីអូន!!អត់ចាំមិនដឹងគាត់កើតឆ្នាំអីគេទេ ព្រោះអីញ៉ុមកើតមកអត់ទាន់គាត់ផង។

ក៖ហ្នូ!!ហើយគាត់ម៉េចដែរបានគាត់អញ្ជឹង?

ខ៖ គាត់ គាត់ស្លាប់ដោយជំងឺប៉ុន្តែញ៉ុមមិនជាគាត់អាយុប៉ុន្មានអីប៉ុន្មាន!!

ក៖ចាំ!!

ខ៖ញ៉ុមអត់ដឹងដែរ!

ក៖ហ្នឹងហើយ អញ្ជឹងមើលនៅក្នុងសំបុត្រកំនើតម្ដាយរបស់លោកយាយឈ្មោះអ៊ុយ ប៊ុន។ខ៖ចាំ!!ក៖ សញ្ជាតិខ្មែរកើតថ្ងៃទី៨ ឧសភា ឆ្នាំ១៩២៣!!

ខ៖ចាំ!!

ក៖ នៅភូមិតាខ្មៅ ឃុំកំពង់សំណាញ់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា។

ខ៖ចាំ!!

ក៖ អញ្ជឹងនៅក្នុងសំបុត្រកំនើតគេបានដាក់បែបហ្នឹង!!

ខ៖ ចាំ!!

ក៖ លោកយាយ លោកយាយអាយុប៉ុន្មានឆ្នាំបានម្ដាយស្លាប់?

ខ៖ កាលគាត់ទឹមតែបែកទៅអាពតហ្នឹង!!

ក៖ហ្នូ!!

ខ៖
ហ្នឹងហើយដូចថាគាត់ជំលៀសចេញទៅគាត់ខូចចិត្តដូចថាផ្ទះទឹមតែធ្វើហើយអញ្ចឹងហាំ!!ហើយដល់គាត់ចេះតែស្តាយផ្ទះសម្បែងហ្នឹងហើយកាត់ក៏ចេះតែកើតទុកទៅដល់ហ្នឹងគាត់ឈឺរ៉ាំរ៉ៃរ៉ាំរ៉ៃដល់ឈឺប្រហែលបានមួយឆ្នាំស្លាប់ទៅ!!

ក៖ ហ៊ឺហើយសមដោយសារអត់មានអីហូបផងហេលោកយាយហេ?

ខ៖ ចាំ!!ហ្នឹងហើយ ហើយគាត់ឈឺហើមជើងហើមដៃ!!!

ក៖ អញ្ចឹងគាត់ស្លាប់??

ខ៖ជំនាន់អាពតហ្នឹង!!

ក៖ ជំនាន់អាពត!!

ខ៖ជំនាន់អាពត!!

ក៖ នៅបានមួយឆ្នាំលោកយាយណោះ?

ខ៖ចាំ!!

ក៖អ៊ិចឹងគាត់ស្លាប់នៅឆ្នាំ១៩៧៦ហើយ!!

ខ៖ចាំ!!

ក៖ដោយសារបានមួយឆ្នាំហើយចុះ!!

ខ៖ មិនដឹងបានប៉ុន្មានឆ្នាំទេកូន ញុំមអត់សូវចាំដែរ!!

ក៖ចាំហ្នឹងហើយ!!

ខ៖ យើងទៅបានមួយឆ្នាំគាត់ស្លាប់!!

ក៖ ហ្នឹងហើយដោយសារអញ្ចេក ១៩៧៥ទឹមតែចូលហ្អ៎!!

ខ៖ចាំ!!

ក៖អញ្ជឹងបានមួយឆ្នាំទៅវា៧៦(១៩៧៦)ហើយ!! ១៩៧៦ហ្នឹងគាត់ស្លាប់ហ្នឹង!!

ខ៖ចាំ!!

ក៖លោកយាយចាំអីគេខ្លះពីម្ដាយលោកយាយអាចរៀបរាប់ពីម្ដាយមើល ថាតើធ្លាប់មានអនុស្សាវរីយ៍អីគេខ្លះជាមួយគាត់អញ្ជឹងទៅណាស់??

ខ៖ មានអីទេនេះកូន ចាំតែនេះពេលដែលឪពុកញ៉ុមផ្លាស់ទៅកោះកុងទៅជាមួយគាត់ហ្នឹងទៅមុនដំបូងរៀនតែដល់តែអត់ពីរៀនទៅ ដល់ពេលគេត្រូវការ គេខ្វះកម្មករធ្វើការនៅមន្ទីរពេទ្យហ្នឹងកម្មករនេះហ្នឹងក៏គេសុំពីភ្នំពេញទៅ គេថាគ្មានអ្នកណាគេទៅទេព្រោះគេថាកន្លែងតំបន់ចាញ់ហាំ!!ស្រុកចាញ់ហាំ!!ឮថាកោះកុងអីសុទ្ធតែកន្លែងចាញ់គ្មានពីណាទៅទេអោយរើសឯហ្នឹងទៅ ហើយក៏អញ្ជឹងលោកដុកត័រហ្នឹងក៏អោយញ៉ុមទៅធ្វើការជាមួយគាត់ជាមួយឪពុកហ្នឹងរហូតអញ្ជឹងទៅ ទាំងពីរនាក់គាត់ទៅ!!

ក៖ចាំ!!

ខ៖ ចាំ!!

ក៖ អ៊ីចឹងលោកយាយកាលមុនជំនាន់ប៉ុល ពតបានធ្វើការធ្វើអីដែរជាមួយឪពុកហេ?

ខ៖ ចាំញ៉ុមបានធ្វើនៅពេទ្យខាងបោកអ៊ុត បោកគក់។

ក៖ តែម្ដាយពេលហ្នឹងបាននៅជាមួយគាត់ដែរមែនទេ?

ខ៖ ចាំគាត់នៅជាមួយខ្ញុំ!!

ក៖ ម្ដាយលោកយាយគាត់កាចឬក៏ស្លូត។

ខ៖ មិនជាកាចអីណាស់ទេកូន!!ដូចថាទៅហ្នឹងឧទាហរណ៍បើសិនជាប៉ូលីសទាហានអីគេបញ្ជូនទៅហ្នឹងគេឈឺប្រពន្ធកូនគាត់ដាក់បបរដាក់ត្រីប្រឡាក់ត្រីអីចេះតែអាំងយកទៅហុចគេតែរហូតហ្នឹង!!

កៈ ហ្ហ៎ចិត្តល្អណាស់អ៊ីចឹង!

ខៈ ចាំហើយថ្ងៃខ្លះកម្ម៉ង់ដង់ប៉ូលីសហ្នឹងសំរាប់ធ្វើគាត់ម៉ែឪមកម៉ែឪអត់ទៅស្រណុកគាត់ចែកហើយគាត់សួរទៅបបរអោយគាត់ហូបអីអញ្ចឹង!!គេសុំគាត់ធ្វើម៉ែធមិធ្វើអីអញ្ចឹងទៅ!!

កៈ ហ្នឹងហើយនិយាយទៅសំរាប់ម្ដាយរបស់លោកយាយគាត់ប្រកបមុខរបរអីគេដែរដើម្បីចិញ្ចឹមគ្រួសារ!!

ខៈ គាត់នៅផ្ទះឪពុកខ្ញុំបានធ្វើការកម្មករពេទ្យជាមួយញ៉ុមហ្នឹង!!

កៈចាំ!

ខៈចាំ!!

កៈ តែគាត់ធ្លាប់ធ្វើស្រែចំការអីទេ?

ខៈ មិនដែលបានធ្វើនៅណោះមានស្រែឯណាធ្វើ។

កៈ និយាយថាមុនពេលទៅទៀតហាំ?

ខៈ មុនពេលហ្នឹងគាត់ធ្វើនៅខាងនេះ នៅស្រុកឪពុកញ៉ុមតាកែវហ្ហ៎!!

កៈហ្ហ៎!!ខៈនៅខាងអ៊ីចឹង ខាងកើតភ្នំតាម៉ៅ។

កៈ ហ៊ឺឆ្ងាយដែរតើ!!

ខៈ
ពីដើមគាត់ធ្វើ!!ដល់ពេលឪពុកញ៉ុមបានធ្វើការនៅពេទ្យធំអញ្ចឹងទៅគាត់ឈប់ធ្វើទៅគាត់នៅភ្នំពេញជាមួយគាត់ហាជាមួយឪពុកញ៉ុមហ្នឹង!!

កៈចាំ!!

ខៈ មកនៅតាខ្មៅហ្នឹងពុកញ៉ុមដល់គេទាមទារបានខេត្តកោះកុងហើយហ្នឹងខេត្តយើងព្រះវិហារនោះ

ក៏គេគាត់អោយអ្នកនេះគាត់ទៅ ទៅផ្នែកខាងពេទ្យហ្នឹង មានដុកទ័រអីហ្នឹងមានអីទៅទាំងអស់គ្នាទៅមានប្រាក់ចាញ់មានអីអ៊ិចឹងទៅឪពុកញ៉ុមអោយគាត់អត់ទៅ អោយប្រាក់ថ្លៃប្រាក់ចាញ់ទៅក៏គាត់ទៅទៅ។

ក៖ ហ្នំអ៊ិចឹងគាត់ទៅតំបន់ដែលចាញ់គេមានប្រាក់ចាញ់អោយទៀត?

ខ៖ ចាំ!!មានប្រាក់ចាញ់ឧទាហរណ៍ថាយើងពីដើមប្រាក់ខែតែ១២០០ទេ!!

ក៖ចាំ!!

ខ៖ ហើយគេថែមប្រាក់ចាញ់អោយ៦០០ទៀតក្នុងមួយខែ!!

ក៖ហ្នំ!!អញ្ចឹងបើសិនជាយើងចាញ់យើងយកលុយទៅមើលណោះ!!

ខ៖ ចាំតែយើងធ្វើការនៅហ្នឹងស្រាប់ហើយយើងមានដូចថាទៅនេះញ៉ុមមិនដែលឈឺផងហ្នឹង គ្រួសារញ៉ុមមិនដែលឈឺទេ។

ក៖ហោងហើយ!!

ខ៖
ហើយបើគេអ្នកឈឺអ្នកចេះគេបញ្ជូនទៅទល់ដែនទៅណាស់ទៅឆ្ងាយៗអញ្ចឹងទៅ!!ក៖ចាំ!!ខ៖ប៉ុន្តែមិនសូវមាន យើងប្រជាជនឈឺទេច្រើនតែកងទ័ព។

ក៖ហ៊ឹៗ!!

ខ៖ចាំ!!

ក៖
ដូចយាយមានដឹងទេថាហេតុអីបានជានៅក្នុងតំបន់នៅកោះកុងឬក៏នៅកន្លែងខាងខេត្តព្រះវិហារអីវ៉ាន់អាហ្នឹងវាចាញ់ម្ល៉េះលោកយាយ?

ខ៖ មិនដឹងជាយ៉ាងម៉េចមីអូនវាឥឡូវមីអូនខ្លះទៅចាញ់គ្រប់គ្នាអញ្ចឹងទៅ!!ហើយបើសិនជាប្រពន្ធទាហានប្រពន្ធអីទៅនៅ នៅខេត្ត នៅខេត្តដងទង់ហ្នឹងនៅនេះហ្នឹងនៅខេត្តហ្នឹងអត់ចាញ់អត់អីទេ

ប៉ុន្តែបើគេបញ្ជូនទៅតាមទល់ដែនទៅតាមអីវ៉ែគ្នាអីអញ្ចឹងតាមទល់ដែនតាអីអញ្ចឹង ចាញ់ពីនោះមកវិញ។

ក៖ចាំនៅស្រុកដងទង់ហ្នឹងហី?

ខ៖ ចាំនៅស្រុកដងទង់ហ្នឹង!!

ក៖ ចាំ!!ពេលហ្នឹងយាយពេលនៅខេត្តកោះកុងហ្នឹងពេលហ្នឹងមនុស្សច្រើនទេពេលហ្នឹង?មើលទៅអ៊ូអររអត់?

ខ៖ កាលពេលហ្នឹងវាអ៊ូអរដែលប៉ុន្តែមិនសូវមានប្រជាជននេះប៉ុន្មានទេ វាច្រើនតែអ្នកធ្វើការគ្រប់ក្រសួងទៅណាស់!!

ក៖ចាំ!

ខ៖ ដូចថានៅជិតៗគ្នាហ្នឹងហាំ!ហ្នឹងទៅដាក់មួយដុំអញ្ចឹងទៅបន្ទាយប៉ូលីសផ្សេង បន្ទាយទាហានផ្សេង!!អញ្ចឹងទៅ!!

ក៖ហ៊ឺៗ!!

ខ៖ ហើយដូចថាសម្តេចទៅបង្កើតវត្តអ៊ីចឹងទៅអីអ៊ីចឹងនៅហ្នឹងអ៊ីចឹងទៅ!!ធ្វើបុណ្យធ្វើអីទៅ។

ក៖ សម្តេចឪហ្នឹងហ្នូ!!

ខ៖ ហ្នឹងហើយ។

ក៖ ដោយសារទោះតែឪឡូវហ្នឹងក៏ដោយញ៉ុមមើលទៅខេត្តកោះកុងក្រមនុស្សណាស់!!

ខ៖ ក្រអត់សូវមានទេ!!

ក៖ ក្រអត់សូវមានអ្នករស់នៅច្រើនទេ!!

ខ៖ចាំ!!

ក៖ឃើញនៅសល់ដីច្រើន ដីអីវ៉ាន់ច្រើន។

ខ៖ រត់ទៅទល់ដែនអីអស់ហើយ!!

ក៖ហ្នឹងហើយអ្នកកោះកុងឥឡូវសម័យឥឡូវរត់ទៅថៃអស់ហើយ!!ចាំទៅធ្វើការនៅថៃ ដោយសារនៅថៃបានលុយច្រើនជាង!!តែឥឡូវ!!

ខ៖ ឥឡូវគេថាធ្វើស្ពានធ្វើអីឆ្លងមកត្រើយម្ខាង ។

ក៖ អានោះស្ពាននោះធ្វើយូរណាស់ហើយ!!

ខ៖ យូរទៅគេធ្វើ អត់ទេស្ពាន់កាលញ៉ុមនៅអត់ទាន់មានទេ!!

ក៖ ចាំហ្នឹងហើយ។

ខ៖តែដល់ឥឡូវឃើញគេធ្វើស្ពានធ្វើអីឆ្លងគេថាសប្បាយជាងមុន !!

ក៖ចាំ!!

ខ៖ ញ៉ុមមិនសូវដឹងដែរ។

ក៖ចាំ!!វាស្អាតអីចឹងណាស់!!

ខ៖ វាជំនាន់មួយជំនាន់ម្នាក់ហ្នឹង!!

ក៖ដោយសារសម័យមុនគេអត់ទាន់អភិវឌ្ឍន៍អីបានច្រើនទេ!!

ខ៖ ចាំ!!

ក៖តែក៏ស្រុកសំបូរសប្បាយណាស់លោកយាយហេ?

ខ៖ ចាំសំបូរសប្បាយណាស់ ល្ងាចៗអីអីចឹងទៅចង់ទៅដើរទៅហូបចំនីសៀមអីអញ្ចឹងទៅ សៀមដូចថាយើងទាមទារបានខេត្តកោះកុង សៀមដែលនៅខេត្តកោះកុងយើង ដែលនៅក្នុងខេត្តយើងវាអត់ទៅណាវានៅហ្នឹងដែរទៅ។

ក៖ចាំ!!

ខ៖ ចាំហើយវាធ្វើអីវ៉ាន់លក់ដូរអីយើងចេះតែល្ងាចឡើងយើងចេះតែហូបទៅអីអញ្ចឹងទៅ!!

កៈចាំ!!ជំនាន់ហ្នឹងលុយអីវ៉ាន់ឬក៏ទំនិញឬក៏របស់របរអីវ៉ាន់វាថ្លៃទេលោកយាយ?

ខៈ គុយទាវយើងមួយចាន៣រៀលហ្នឹង!!

កៈហ្អ៎!!

ខៈ នំបញ្ចុកតែ១រៀលចំហៀងអីហ្នឹង ១រៀលប្រាំកាក់អីហ្នឹងយើងហូបឆ្អែតបាត់ហើយ។

កៈចាំ ដល់ពេលឥឡូវវិញ!!

ខៈ ចាំញ៉ុមពីដើមប្រាក់ខែញ៉ុមប្រាក់ខែតែ១២០០ទេ ចិញ្ចឹមខាងម៉ែក្មេកផងចិញ្ចឹមខាងប្រពន្ធខាងម៉ែខាងប្រពន្ធអីផងក៏នៅមិនអស់ដែរ!!

កៈចាំ!!

ខៈ តែឥឡូវអត់គ្រាន់ទេកូនអើយ!!

កៈ ហ៊ីឥឡូវពិបាកណាស់យាយអើយ!!

ខៈចាំ!!

កៈ ញ៉ុមនៅពីក្មេងញ៉ុមអាយុ២០មិនទាន់៣០ផងយាយហាំ!!

ខៈចាំ!!

កៈនៅពីក្មេងនំបញ្ចុកទិញ៣០០ហ្នឹង!!

ខៈហ្នឹងហើយ!!

កៈ ហើយឥឡូវមិនបាច់ទេ ១០០០គេមិនលក់អោយយើងទេ!!

ខៈ មាសមួយជី២០០ហ្នឹង !!

កៈហ្អ៎!!

ខៈ ឈ្នួល២០រៀលហ្នឹងកាលហ្នឹងហ្អ៎!!

កះហ្អ៎!!ដល់ពេលឥឡូវមិនបាច់លូក!!

ខះ កាលហ្នឹងមាសថោកអញ្ចឹងគ្មានអ្នកណាគេសង្វាតទិញមាសទិញអីទុកទេគ្មានទេ!!

កះ ចាំវាគិតវាអត់អីហ្អ៎លោកយាយ!!

ខះ ហ្នឹងហើយ!!

កះ ដូចជាសម័យឥឡូវមាសឡើងថ្លៃណាស់ មិនដឹងថាអនាគតទៅមាសចុះថោកឬក៏មាសឡើងថ្លៃបន្ថែមផងហ្នឹង!!

ខះ ចាំឥឡូវមាសថ្លៃ!!

កះ ចាំអញ្ចឹងមួយៗគិតថាបើឧបមាថ្ងៃក្រោយទៅមាសហ្នឹងចុះថោកធ្វើម៉េចទៅ!!

ខះ ហ្នឹងហើយ!!

កះ អញ្ចឹងបើទិញឥឡូវ វាមិនខាន តែបើសិនជាថោកឡើងថ្លៃវិញវាមិនសូវអីទេណាស់ អាហ្នឹងចំនេញរកស៊ី!!

ខះ ហ៊ីមីអូនអើយឥឡូវរកតែអីអោយចែកចៅពាក់មិនបានផងបានអីទិញទុក!!មែនតើ!!

កះ តែបើពេលមុនមកឥឡូវវិញទិញទុកមិនបាច់បណ្តោយ!!

ខះ មុនអត់មានលុយអត់មានកាក់អីមីកូនណោះឆ្លងទន្លេ វះផងអីផង រកលុយណាត្រូវការបង់លុយរដ្ឋផងអីផងញុំមយករដ្ឋមួយដែរ អត់លុយ ណាមីយុនមីចៅហ្នឹងភ្ជាប់ពាក្យថ្ងៃមុនហ្នឹង
ដល់ម្សិលមិញអត់លុយដោះអាចិញ្ចៀនភ្ជាប់ពាក្យគ្នាយកទៅលក់បាត់ទៅ!!

កះ អើរ!!ហើយម៉េចទៅដោះចិញ្ចៀនភ្ជាប់ពាក្យវិញ??

ខះ បង់រដ្ឋ អត់លុយបង់!!

កះ ហ្អ៎!!ហើយចុះបើសិនជាខាងប្រុសដឹងម៉េចទៅ?

ខ៖ ហ៊ីវាចេញចូលរាល់តែថ្ងៃ វាអាងវាភ្ជាប់ពាក្យហើយ វាអាង វាចេញចូលវាអត់ឃ្លាតទេ ព្រោះអីវាភ្ជាប់ពាក្យហើយហើយ។

ក៖ចាំ!!តែដឹងថាយកចិញ្ចៀនយកអីទៅអត់?

ខ៖ញ៉ុមអត់ប្រាប់ផងល្ងាចមិញយកទៅ!!

ក៖ តែមិនបាច់មាត់ទេ លោរថ្ងៃណាមានលុយទៅទិញមកវិញមក!!

ខ៖ ហ្នឹង!!នឹកឃើញថាចាំបើកលុយថ្ងៃ១០ចាំទិញសងវាវិញ!!

ក៖ លោកយាយពេលនៅ អើរងាកមកម្ដាយវិញ ម្ដាយរបស់លោកយាយក្រៅពីមុនទៅកោះកុងហ្នឹងគាត់ធ្វើស្រែចំការ?

ខ៖ ចាំ ពីដើមគាត់ធ្វើស្រែខាងតាកែវណោះ!!

ក៖ចាំ!!ហើយមានធ្វើអីគេផ្សេងពីធ្វើស្រែហ្នឹងទេ?

ខ៖ អត់ទេ!!អត់ផង។

ក៖ ហ្ហ៎!!ដាំដំនាំអីអត់?

ខ៖ អត់ទេអត់ធ្វើ ពេលនៅកំពង់សំណាញ់យើងមានអីដាំទៀត!!

ក៖ ពេលយើងទៅនៅតាកែវណោះហាំ??

ខ៖ ទៅតាកែវយើងអត់មានអីដាំផង។

ក៖ ដាំតែស្រូវមួយទេហេ?

ខ៖ដាំធ្វើតែស្រូវតែមួយមុខ!!ចាំ!!

ក៖ ចាំ តែលោរនៅហ្នឹងគេមានធ្វើស្ករត្នោតអីអត់ ព្រោះលោរនៅហ្នឹងសំបូរត្នោតណាស់!!

ខ៖ អត់ទេ ស្ករត្នោតមានតែនៅខាងលិចទេ!!ឯយើយម៉ុំភ្នំតាម៉ៅណោះ!!

ក៖ហ្ហ៎!!

ខ៖ យើងម្ដុំទំពាំងសាបទំពាំងអីអាហ្នឹងគេសំបូរដើមត្នោត ហើយយើងខាងកើតថ្នល់ផ្លូវជាតិលេខ២អត់សូវមានទេ!!

ក៖ហ្អូ!!

ខ៖ ទាល់តែមកខាងលិចបានមានច្រើន!!

ក៖ បានសំបូរបានអីវិញ!!

ខ៖ ចាំ!!ខាងទំពាំងសាបបានសំបូរច្រើន តាំងពីដំឡូងផ្កាដំឡូងអីឡើងមក ខាងនៅម្ដុំស្រុកសំរោងយោងណោះ!!

ក៖ចាំ !!ស្គាល់ហើយ!!

ខ៖ ចាំហ្នឹងហើយទីហ្នឹងបានសំបូរ!!ហើយញ៉ុមនៅខាងកើត!!

ក៖ ហើយលោកយាយដែរ! ចុះបងប្អូនមានអ្នកនៅខាងលិចហ្នឹង មានអ្នកធ្វើស្ករត្នោតហ្នឹងមានដាំជំនាំអីអត់?

ខ៖ អត់ដែលនេះផង ព្រោះអីពីដើមដូចថាយើងកាន់ទីគ្នា!!

ក៖ កាន់ទីទៀត?

ខ៖ចាំ!!

ក៖ ម៉េចវិញទៅលោកយាយអាចប្រាប់បន្តិចមើលម៉េចទៅ??

ខ៖ ព្រោះអីអ្នកនៅខាងត្រពាំងសាបសុទ្ធតែអ្នកខាងធ្វើអំពើធ្វើអីពីដើមណាស់!!

ក៖ចំ!!

ខ៖ ហ្នឹងហើយ!!

ក៖ ចូលទឹកដីគ្នាមិនបាន!!

ខ៖ ហ្នឹងហើយ កាលណាយើងទាស់គ្នាអីបន្តិចបន្តួចអីដើរ មានអីដីពូនដីខ្សាច់អីហ្នឹង យើងដើរឈ្លូសដើរអីហ្នឹង
យើងហើមជើងហើមដៃអីទៅណាស់!!ម្ល៉ោះហើយពួកខាងញ៉ុមមិនសូវមកទេ!!

ក៖ ចា៎!!វាមានរឿងអញ្ចឹងមែន?

ខ៖ ចា៎!!ហើយមានអំពើរមានអី អើរហើយដូចកាលពីដើមគេមានឃីកេឃីអី សុទ្ធតែអ្នកមានចេះអញ្ចឹងៗអី ឃីកេយើងបានពិរោះបានល្អមើលអញ្ចឹងទៅណាស់!!

ក៖ចា៎!!អូសអ៊ីចឹងពិបាកណាស់!!

ខ៖ ម្ល៉ោះហើយ ដូចថាកាន់ទីគ្នាអីខាងណោះខាងណោះអីទៅ!!ព្រោះអីខាងទំពាំងសាបហ្នឹងច្រើនតែគ្រូ!!

ក៖ចា៎!

ខ៖ ធ្វើអំពើអីអញ្ចឹងទៅ!!

ក៖ លោកយាយញ៉ូមឆ្ងល់ថាអ្នកដែលធ្វើអំពើហ្នឹងគេអត់ខ្លាចបាបទេអី?

ខ៖ ហ៊ីមិនដឹងម៉េចទេកូនអើយ!! ហ៊ីបើគេមិនខ្លាចបាបគេមិនធ្វើទេ!!

ក៖ ធ្វើអោយអ្នកដទៃឈឺចាប់!!

ខ៖ គ្រាន់តែថាទិញស្រូវអ្នកមកពីចំងាយអញ្ចឹតងទៅខ្លះទៅអញ្ចឹង មុនៗញ៉ុមតាញ៉ុមដែលធ្លាប់ដឹង ពួកខាងព្រៃវែង ពវែងពងទឹកនេះមិនទៅទិញស្រូវទិញអង្ករអីហើយគ្រាន់តែខុសគ្នាបន្តិចបន្តួចហ្នឹង ហើយគ្នាទៅពីនេះទៅគ្នាអត់ដឹង ស្រាប់តែខាងណោះថា ថាដូចថាអត់ត្រូវគ្នា ញ៉ុមដូចថាផ្ញើរអង្ករមួយកំប៉ុងដូចថាទៅផ្ទះអីផង យើងអត់ដឹងយើងឆ្លើយទទួលទៅ តែថាយកអញ្ចឹងទៅដល់ផ្ទះគ្នាដូចថាគ្នាបាន២ ៣ថ្ងៃ ខ្លះបាន៧ថ្ងៃអញ្ចឹងហា!គឺពោះដូចកើតទៀចអញ្ចឹងហា៎!!គឺហើមឡើង ហើមពោះហើមអីអញ្ចឹងទៅណាស់ងាប់អត់ប្រយោជន៍អញ្ចឹងទៅ!!

ក៖ ហ៊ឺ!!ទៅអញ្ចឹងទៅ!!

ខ៖ចាំហ្នឹងហើយ!!អញ្ចឹងទៅបានម្ល៉ោះហើយអត់មានអ្នកណាសួរនេះទេ!! ទឹមតែមកឥឡូវទេ ត្រពាំងសាបយើងឥឡូវទឹមតែមកយើងបែកអាពតនេះហើយទេ!! ហើយគ្រូឥឡូវខាងហ្នឹង ក៏រៀងសាបក៏មិនសូវមានដែរ!!

ក៖ លោកយាយញ៉ុមឆ្ងល់អញ្ចេក ហេតុអីអាអ្នកប៉ុនធ្វើគ្រូធ្វើអីហ្នឹង ពេលជំនាន់អាពតហា!!មិនព្រមធ្វើអាពួកអស់ហ្នឹងអោយងាប់អស់រលីងទៅ??

ខ៖ អញ្ចឹងបានញ៉ុមឆ្ងល់ដែរ។

ក៖ហើយម៉េចអីចឹងសង្ស័យគ្រូហ្នឹងខ្លាចកាំភ្លើងដែរ!!

ខ៖ ខ្លាចកាំភ្លើងដែរ!!មិនដឹងរត់ទៅណាអស់ទៅគ្រូហ្នឹង!!

ក៖
ហ៊ឺ!!មើលសង្ស័យតែធ្វើអាគមន៍មិនទាន់នឹងគ្រាប់កាំភ្លើងហា!!តែញ៉ុមគិតថា!ហួយវាវញ៉ែវញ៉ៃ ណាស់រឿងហ្នឹងហ្ន៎!!

ខ៖ ចាំ!!

ក៖ ធ្វើបានដាក់តែអានាក់អត់ដឹងខ្លួនហ្នឹង។

ខ៖ អ្នកអត់ដឹងហ្នឹង បានតែអានាក់ស្លូតត្រង់ហ្នឹង!!

ក៖ចាំ!!

ខ៖ ដល់អាគេនេះមកដូចមិនហ៊ានអីជាមួយគេផង។

ក៖ ហ៊ឺទៅអីចឹងទៅណោះ?

ខ៖ ចាំ !!

ក៖ វាអត់ត្រូវសោះម៉ង!!លោកយាយចំនុចកន្លែងណាដែលស្រលាញ់ម្ដាយជាងគេ?

ខ៖ ហ៊ឺ ស្រលាញ់វាស្រលាញ់ហើយកូន ដល់តែពេលយើងចាស់ខ្លួនទៅទៅណាទៅធ្វើការមានកូនមានចៅគាត់នៅមើលនៅថែអញ្ចឹង

យើងទៅធ្វើការដល់ពេលបើកលុយមកយកមកប្រគល់អោយគាត់អស់មែនប៉ុន្តែព្រលឹមឡើង
បានសុំលុយគាត់ទៅធ្វើការពេលព្រឹកវិញ
ហើយគាត់កូនចៅឈឺថ្កាត់វិញនៅលើគាត់ទាំងអស់ម្លោះហើយនឹកឃើញថានឹកបារម្ភ
នឹកស្រលាញ់គាត់អញ្ចឹងដែរ!!

ក៖ចាំ!!

ខ៖
តែអត់មានបានធ្វើបុណ្យអោយគាត់អីត្រឹមត្រូវស្រួលប្រួលទេ!!ព្រោះអីគេទៅស្លាប់នៅអាពត
ណោះមានអីធ្វើ!!

ក៖ អញ្ចឹងសពគាត់ម៉េចទៅយាយ?

ខ៖ សពគាត់ហ្នឹង កាលយើងទឹមបានមួយឆ្នាំហ្នឹងគេនៅអាចដុតបានទេ!!

ក៖ហ៊ុំៗ!!

ខ៖បើដល់ពេលចូលដល់ពីរឆ្នាំនេះមកគេអត់អោយដុតទេ សុទ្ធតែកប់ចោលកប់អីអញ្ចឹងទៅ!!

ក៖ អ្នកណាគេធ្វើបុណ្យគឺអត់បានម៉ងហេយាយ?

ខ៖ កាលពេលគាត់ស្លាប់ហ្នឹងញ៉ុមមានលោកមានអីដែរ!!

ក៖ហ្ហ៎!!

ខ៖ បានដុតហាំ មានលោកមានអីនិមន្តទៅធ្វើការបូជាគាត់អីទៅ។

ក៖ ពេលហ្នឹងអត់ទាន់ខ្លាំងហាំ!!

ខ៖
ចាំ!!ដល់ពេលយូរៗទៅវាលែងអោយមានម៉ងលោកសង្ឃអីក៏វាអោយសឹកដែរ!!វាអត់អោយមា
ន
តែញ៉ុមទៅអាពតហ្នឹងញ៉ុមអត់សូវពិបាកទេ!ព្រោះញ៉ុមចេះដេរអីចឹងគេហៅអោយទៅដេរអាវ
ដេរអីអោយគេអីនៅវត្តអីចឹងហ្ហ៎!! គេមានម៉ាស៊ីនដេរគេហ្ហ៎!!

កៈចាំ!!

ខៈ ដេរមួកស្លឹកមួកអីអោយគេអញ្ចឹងទៅ!!

កៈ អញ្ចឹងក៏រួចខ្លួនអញ្ចឹងដែរមួយគ្នាទៅ!!

ខៈចាំចាំ!!

កៈ ចាំអញ្ចឹងលោកយាយចូលដល់ឪពុកវិញម្តង ឪពុកឈ្មោះអីគេវិញដែរ?

ខៈ គឹម អ៊ែល!!

កៈ គឹម អ៊ែល ហ្នឹងហើយ!!ចាំអញ្ចឹងសំរាប់សំបុត្រកំណើតរបស់ឪពុករបស់លោកយាយគាត់ឈ្មោះគឹម អ៊ែល គាត់កើតនៅក្នុងថ្ងៃទី០៥ខែតុលា ឆ្នាំ១០២៥ !!

ខៈចាំ!!

កៈ នៅក្នុងឃុំអើរត្រគៀត ស្រុកបាទី ខេត្តតាកែវ។

ខៈ ភូមិត្រគៀត ហ្នឹងហើយ!!

កៈ ភូមិត្រគៀត ឃុំត្រគៀត ស្រុកបាទី ខេត្តតាកែវ ប្រទេសកម្ពុជា!!អ៊ីចឹងខាងឪពុកគាត់នៅតាកែវណោះទេ!!

ខៈ ចាំ!!

កៈ នៅត្រគៀតណោះ!!

ខៈចាំ!!

កៈ ញ៉ុមឮតែត្រគៀតៗញ៉ុមអត់ដែលស្គាល់សោះ!!

ខៈ ត្រគៀតចំប៉ី គេដាក់ខុសទេនេះហ៎!! នៅភូមិត្រគៀត ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ!!

កៈ ហ្វូអញ្ចឹងនៅភូមិត្រគៀត ឃុំចំប៉ី!!

ខ៖ នៅភូមិត្រគៀត ឃុំចំប៉ី អានេះគេដាក់ខុសទេ ស្រុកបាទី គាត់នៅតាកែវ។

ក៖ ចេះតែដាក់ៗទេមិនស្រួលហ៎!!

ខ៖ ចេះតែដាក់ៗ មួយចំបក់យើងបោះឆ្នោតហ្នឹងគេចេះតែហៅទៅធ្វើទៅ!!

ក៖ចាំហ្នឹងហើយ អ៊ីចឹងលោកយាយសំរាប់ឪពុករបស់លោកយាយ ចាំឆ្នាំខ្មែរគាត់ទេ គាត់កើតឆ្នាំអីគេវិញ?

ខ៖ គាត់ដឹងតែគាត់ឆ្នាំមមី!!

ក៖ចាំ សត្វសេះ។

ខ៖ មិនដឹងខែអីទេ ប៉ុន្តែញ៉ុមតែគាត់ឆ្នំាមមី!!

ក៖ ចាំហ្នឹងហើយ!! ខែតុលាដែរហ្នឹងនេះបើសិនជាគាត់កើតត្រូវនឹងនេះមែនគាត់កើតអំឡុងៗពេលភ្ជុំដែរឬក៏ហើយ ភ្ជុំហ្នឹងខែភទ្របទដែរហ្នឹងមិនស្រួល!!

ខ៖ មិនដឹងខែណា!ចាំ!!

ក៖ ភាគច្រើនយើងអត់សូវចាំខែខ្មែរយើងទេណោះ?

ខ៖ចាំចាំ!!

ក៖ គេអត់សូវពេញនិយមនិយាយហាំ!!

ខ៖ចាំ!!

ក៖ អញ្ចឹងលោកយាយសំរាប់ឪពុករបស់លោកយាយសំរាប់ក្រៅពីធ្វើ ធ្វើពេទ្យហោយាយ?

ខ៖ ចាំ កាលមុនគាត់ធ្វើស្រែនៅតាកែវហ្នឹង!!

ក៖ ចាំ!!

ខ៖ នៅត្រគៀតចំប៉ីហ្នឹង!! ដល់ហើយគាត់មកធ្វើកម្មករនៅពេទ្យធំនៅពេទ្យព្រះកេតមាលានោះ!!

ក៖ចាំ!!

ខ៖ គាំតនៅធ្វើនៅហ្នឹងវិញ!!

ក៖ ញ៉ុមឆ្ងល់ថាហេតុអីបានគេដូរដាក់ពេទ្យធំវិញ ពេទ្យព្រះមន្ទីរពេទ្យព្រះកេតុមាលាសោះហ្នឹង!!

ខ៖ ហ្នឹងហើយគេដាក់ ខ្លះគេហៅពេទ្យធំពេទ្យអីអញ្ចឹងទៅ ស្រេចតែគេហៅ!!

ក៖ គេដូរឈ្មោះ ចាំ!!

ខ៖ កាលមុនព្រះកេតមាលាទេ!!

ក៖ ចាំ ឥលូវក៏នៅតែព្រះកេតុមាលាដែរ!!

ខ៖ ចាំ!!

ក៖ នៅតែគេហៅថាពេទ្យធំពេទ្យធំហ្នឹង!!

ខ៖ ចាំ!!កាលពីដើមពេទ្យហ្នឹងធំជាងគេ!!

ក៖ ហ្ហំ!!អ៊ីចឹងបានគេហៅពេទ្យធំពេទ្យធំ!!

ខ៖ ចាំ!!ពីដើមអ្នកណាក៏ទៅតែពេទ្យហ្នឹងដែរ ពីដើមអ្នកណាត្រូវវះកាត់អីវាមិនទាន់មានមានតែពេទ្យហ្នឹងមួយទេ!!
ដល់អ៊ីចឹងទៅបង្កើតគន្ធបុប្ផាអីអញ្ចឹងទៅច្រើនមានតែកន្លែងហ្នឹងហ្នឹង!!

ក៖ចាំ!!

ខ៖
ហើយដែលយើងនៅតាមភូមិតាមអីអញ្ចឹងតិចតួចហ្នឹងអញ្ចឹងហ្នឹង!!តែពីដើមពេទ្យហ្នឹងវាធំជាងគេ!!

កៈ តែគ្រាន់តែពេទ្យ ពេទ្យប្រហែលខ្លាំងហើយពេលហ្នឹង លោកយាយហេ ?

ខៈចាំ!!

កៈ ជួយប្រជាជនបានច្រើនហាំ!!

ខៈ ជួយបានច្រើន!!

កៈ ដោយសារពេលហ្នឹងបើសិនជាប្រជាជនអត់មានលុយអីវ៉ាន់ទៅពេទ្យអីវ៉ាន់អស់លុយទេ?

ខៈអត់អស់ទេកូន!!

កៈ ស្រួលណាស់អ៊ីចឹង។

ខៈ ហើយពេទ្យមានបាយអោយហូបទៀត!!ដូចខ្ញុំអីកាលផ្លាស់ពីកោះកុងហ្នឹងមកនៅស្រុកស្រែអំបិលហ្នឹងក៏នៅក្នុងអនុខេត្តកោះកុងដែរ។

កៈចាំ!!

ខៈ នៅអនុខេត្តកោះកុងដែរ!!ប៉ុន្តែអនុខេត្តកំពង់សិលា ប៉ុន្តែញ៉ុមមកនៅហ្នឹងជាមួយប្តី ប្តីធ្វើទាហាននោះ!! បានស្នាមអស់ពេញខ្លួនងាប់អស់កូន២ទៀតហ្ន៎!!

កៈ ចាំមើលតិចទៀតចាំសួរថីបានលោកយាយស្នាមភ្លើងឆេះហ្នឹង!!

ខៈ ហ្នឹងហើយ។

កៈ ហ្នឹងហើយចាំតិចទៀត ឥឡូវសួរឪពុកសិន!!

ខៈចាំ!!

កៈ អញ្ចឹងឪពុកគាត់ធ្វើពេទ្យ?

ខៈ ចាំធ្វើពេទ្យជាមួយញ៉ុមហ្នឹងដែរ!!

កៈ ចាំ!!ខាងដុកទ័រម៉ងឬក៏នេះ??

ខៈអត់ទេកម្មករដែរ។

កៈ កម្មករអនាម័យនៅពេទ្យហ្នឹងហោ?

ខៈចាំ បោសច្រាស់អីអ៊ិចឹងទៅ!!

កៈ ហ្ហូអញ្ចឹងហោ?

ខៈ ចាំ!!

កៈ ហើយម្ដាយគាត់មកជួយធ្វើអីអញ្ចឹងដែរទៅហោ?

ខៈ អត់ទេគាត់អត់មកនេះទេ !!

កៈ នៅតែផ្ទះទេ?

ខៈ គាត់នៅផ្ទះជួយមើលកូនញ៉ុមអីអញ្ចឹងទៅណាស់!!ចាំ!!

កៈហ្ហូហ្នឹងហើយ
អ៊ីចឹងលោកយាយសំរាប់អើរឪពុករបស់លោកយាយគាត់នៅមានជីវិតឬក៏គាត់អនិច្ចាកម្ម?

ខៈអត់ទេគាត់ស្លាប់ហើយ។

កៈ គាត់អនិច្ចាកម្មពេលណាដែរយាយ?

ខៈ គាត់ស្លាប់ពេលនឹងបែកអាពតហ្នឹងប្រហែល៣ ៤ឆ្នាំដែរហ្នឹង!

កៈហ្ហូ!!

ខៈ ព្រោះគាត់បែកមកហ្នឹងគាត់បានបួសនៅវត្តព្រែកសំរោងហ្នឹងអីអ៊ិចឹងដែរ!!

កៈហ្ហូ!!

ខៈ
ដល់ពេលហើយបានគាត់មកយកប្រពន្ធចុងនៅអាយើងនៅផ្សារដើមអំពិលនេះថាអាខាងគេលក់កាហ្វេយើងពីដើមថាអាខាងបែកយើងមុខទៅអញ្ចេះហ្នឹង!!

កៈ ចាំ !!ស្គាល់ហើយ ស្គាល់ហើយ!!

ខ៖ ផ្លូវអាបំបែកជាបូនហ្នឹង!!

ក៖ស្គាល់ ស្គាល់!!

ខ៖ ខាងនៅអាខាងកើតផ្លូវហ្នឹង!!

ក៖ចាំ!!

ខ៖ ខាងកើតផ្លូវខាងត្បូងផ្លូវទៀត!!ហ្នឹងប្រពន្ធហ្នឹងផ្ទះប្រពន្ធចុងគាត់ហើយ!!

ក៖ចាំ!!

ខ៖ គាត់នៅជាមួយប្រពន្ធចុងហ្នឹងអើរថាគាត់ស្លាប់បានប្រហែល១៥ ១៦ឆ្នាំហើយគាត់ស្លាប់!!

ក៖ ហ្វូអញ្ចឹងយូរដែរហើយ មិនមែន៣ ៤ឆ្នាំទេ!!

ខ៖ ចាំចាំ!!

ក៖ ហើយអញ្ចឹងក៏ការជាមួយប្រពន្ធក្រោយហ្នឹងទៅហេ?

ខ៖ចាំ!!

ក៖ ហើយនៅបានប៉ុន្មានឆ្នាំបានគាត់ស្លាប់ទៅលោកយាយ?

ខ៖ គាត់មើលគាត់រៀបជាមួយយាយក្រោយហ្នឹងបានប្រហែល៣ ៤ឆ្នាំដែរហ្នឹងបានស្លាប់។

ក៖ អើរដល់អ៊ីចឹងយាយក្រោយម្តាយចុងរបស់យាយហ្នឹងគាត់ស្លាប់ដែរហើយហេ?

ខ៖ គាត់ទឹមតែស្លាប់ប្រហែល២ឆ្នាំហ្នឹងទេ យាយហ្នឹងហ្វូ!!

ក៖ របៀបថា គាត់ចាស់ទៅគាត់ចេះតែយកចេះតែមើលថៃគ្នាទៅយាយ?

ខ៖ ចាំចាំ!!

ក៖ តាមអញ្ចឹងទៅ!!

ខ៖ ប្រហែលជា២ ៣ឆ្នាំហើយយាយហ្នឹង!!យ៉ាងច្រើន៣ឆ្នាំទេយាយហ្នឹងហ្វូ!!

កៈហ៊ឺៗ!!

ខៈ ដោយសារឪពុកញ៉ុមស្លាប់ប្រហែលជា៨ ៩ឆ្នាំហើយ!!

កៈ ចាំយូរដែរហើយ!!

ខៈ ចាំគាត់ស្លាប់យូរដែរហើយ!!

កៈ អ៊ីចឹងលោកយាយសំរាប់អើរ!! បែកអាពតបាន១៥ឆ្នាំបានគាត់ស្លាប់ប៉ុន្តែអត់ត្រូវទេហី? ប៉ុន្តែមិញលោកយាយមីញប្រាប់ថាបែកអាពតបាន១៥ឆ្នាំបានគាត់ស្លាប់អញ្ចឹងបែកអាពតឡើង៣០ឆ្នាំ!!

ខៈ ហ្នឹងហើយបាន១៥ឆ្នាំបានគាត់ស្លាប់។

កៈហ្ហ៎!

ខៈ ហើយមីចៅ ចៅអស់ហ្នឹងកើតមិនដែរទាន់ផងហ្នឹង!!ចៅអាយុ២០ហើយកើតមិនដែលទាន់តាផងហ្នឹង!!

កៈ ហ្ហ៎អ៊ិចឹងមិនមែនស្លាប់៨ ៩ឆ្នាំមុនទេ!!

ខៈ ចាំ!!

កៈ អ៊ិចឹងវាឡើង១០ឆ្នាំជាងមុនហើយ!!

ខៈចាំ!!

កៈ អញ្ចឹងបានត្រូវ!!វាចូល២០ជាងហើយព្រោះអីចៅញ៉ុមនេះវា២០ហើយវាកើតអត់ទាន់តាផង!!

កៈចាំ!!អត់ទាន់តាទូតហោ?

ខៈ ចាំ!!

កៈ លោកយាយឪពុករបស់លោកយាយគាត់ជាមនុស្សចរិកម៉េចដែរ?

ខ៖
គាត់ដូចជាអ្នកយកឧស្សាហ៍គេអីចឹងដែរ!!គាត់នៅពេទ្យនៅអីអញ្ចឹងទៅអ្នកណាឈឺអីគាត់ចេះតែប្រាប់យាយម៉ែញ៉ុមអីហ្នឹងគាត់ចេះតែបបួលគ្នាយកបាយយកសម្លរយកទៅអោយអីចឹងទៅ!!!!

ក៖ហ៊ឺៗ!!

ខ៖ យកម្ហូបយកទៅអោយពេលព្រលឹមឡើងមានអីហុចអោយខ្លះទៅគាត់ចេះតែហុចទៅ!!ក៖ចាំ!!ខ៖ ចាំ!!

ក៖ គាត់ចិត្តល្អដែរហ្នឹងលោកយាយ?

ខ៖ចាំ!!!

ក៖ គាត់អើរនិយាយទៅ!!

ខ៖ គាត់នឹកឃើញថាកូនគេកូនយើងគាត់អត់មានម៉ែឪមកជាមួយអញ្ចឹងទៅណាស់!!

ក៖ហ្នឹងហើយ!!

ខ៖ចាំ!!

ក៖ចងចាំកន្លែងណាជាងគេជាមួយឪពុក? អនុស្សាវរីយ៍មើលមានអីដូចគាត់ដែលនាំលោកយាយដើរលេងណាអីនៅពីតូចអត់?

ខ៖ ញ៉ុមចាំតែគាត់ខំទៅធ្វើការធ្វើអីខំនៅជួយចិញ្ចឹមយើងតាំងពីទូចរហូតមកហើយយើងមិនទាន់បានការងារធ្វើ គាត់ផ្លាស់ទៅកោះកុង គាត់ខំស្រវែស្រវ៉ាអោយបានពីដើមយើងទៅមិនមែនស្រួលឯណា!!មិនដែលមានកប៉ាល់ហោះជិះណា
ដែលកប៉ាល់ហោះស្អីគេដាក់ គេហៅសាកាតានោះ!!

ក៖ចាំ!

ខ៖ កប៉ាល់ហោះទាហានណាស់!!

ក៖ចាំ!!

ខ៖ គេដឹកឡានទៅគេដឹកអីវ៉ាន់ យើងសុំគេ ហើយពីដើមតឹងណាស់មីអូនអើយ យើងទៅតាមឪពុក
ហើយខ្ញុំក៏នៅជំទើរដែរ!!ទៅជាមួយម៉ែហ្នឹង!!ទៅសុំច្បាប់យើងពីដើមនៅផ្សារអី!!ផ្សារបឹងកេងកងគេដាក់អើរកន្លែងសុំសំបុត្រកប៉ាល់ហោះសុំអីហ្នឹង!!ទៅសុំគេបានតែម្នាក់ទៀតខ្ញុំអត់បានទៀតប៉ុន្តែដូចគេទាហាននៅយាមខាងមុខហ្នឹង!!គេឃើញម៉ែញ៉ុមចេះតែទន្រឹកៗទៅសុំអញ្ចឹងគេ គេឃើញគេអានិត ដល់ពេលបានអាក្រដាសហ្នឹងកាន់មកម៉ែញ៉ុមគាត់ធ្វើមុខជូរ ហើយគេសួរថាម៉េចអ៊ំបានធ្វើមុខជូរម្ល៉េះ?ហើយកូនអ្ហើយខ្ញុំមានម៉ែមួយកូនមួយហើយមានសំបុត្រតែមួយកូនអត់បានទៅផង
ញ៉ុមមើលទៅប្រហែលជាអត់ទៅវិញហើយ!!ហើយអានាក់យាមហ្នឹងថាអ៊ំអើយឥឡូវអ៊ំឯងម៉ោង៥បានញ៉ុមចេញទៅផ្ទះអ៊ំឯងម៉េចៗចាំទៅជាមួយញ៉ុមទៅ ចាំញ៉ុមយកទៅផ្ញើរនឹងគេ ហើយវាយកទៅផ្ញើរអ្នកបើកកប៉ាល់ហោះហ្នឹងមែន!!
ទៅដល់ហ្នឹងគេថ្លឹងអីវ៉ាន់ដាក់ពីបៗអញ្ចឹងទៅ
ដល់វាណោះវាយកញ៉ុមទៅផ្ញើរថាម៉ែញ៉ុមហ្នឹងម៉ែវា ហើយញ៉ុមហ្នឹងប្អូនគាត់អញ្ចឹងទៅណាស់!!

ក៖ចាំ!

ខ៖ហ្នឹងហើយ រួចយកទៅផ្ញើរអញ្ចឹងទៅ ហើយបើហ្អែងអត់អោយម៉ែអញទៅបើហ្អែងមិនអោយប្អូនអញទៅបានអាណានៅមើលបើអញទៅធ្វើការបាត់ៗហ្នឹង
វាមកយាមនៅភ្នំពេញនេះនោះ!!ហើយបើហ្អែងមិនអោយទៅបានអីមើល!!ក៏គេទំលាក់អីវ៉ាន់គេចោលខ្លះទៅ អោយយើងឡើងទៅជាមួយអញ្ចឹងទៅ បានបានទៅជាមួយបានបានទៅជួបនឹងឪពុកនៅណោះហ្នឹង!!

ក៖ ហ្នឹងហើយ អ៊ីចឹងអនុស្សាវរីយ៍ជាមួយឪពុក។

ខ៖ នឹកឃើញអានិតគាត់ អានិតគាត់ខំតស៊ូជាមួយយើងដែរ!!

ក៖ ហ្នឹងហើយ។

ខ៖ចាំ!!

ក៖ តែងតែមានហើយឪពុកម្តាយនឹងកូន!!

ខ៖ចាំ!!

ក៖
ចាំ!!អញ្ចឹងលោកយាយសំរាប់ចូលដល់ជីដូនជីតាខាងម្ដាយសិន!!យាយឈ្មោះអីគេវិញយាយខាងម្ដាយហាំ?

ខ៖ យាយខាងម្ដាយ ឈ្មោះ ឈ្មោះអីទេនេះ!!ឪពុកដឹងតែតាអ៊ុយ ម្ដាយឈ្មោះអីទេ!!យាយអ៊ឹម!ក៖យាយអ៊ឹម!!ស្គាល់ត្រកូលគាត់ទេយាយ?

ខ៖ ត្រកូលគាត់អត់ស្គាល់ផង!!

ក៖ អញ្ចឹងស្គាល់តែឈ្មោះថាយាយអ៊ឹម?

ខ៖ចាំ!!យាយអ៊ឹម!!

ក៖យាយកើតទាន់យាយអ៊ឹមទេ?

ខ៖ ខ្ញុំអត់ទាន់ផងកូន ម៉ែញ៉ុមគាត់កំព្រាតាំងពីទូចដែរ!

ក៖ហ្ហ៎!!

ខ៖តាំងម្ដាយគាត់ស្លាប់តាំងពីទូចអត់មានឪពុកម្ដាយទេនៅជាមួយបង។

ក៖ ហើយយាយរបស់យាយហ្នឹងអ្នកស្រុកមកពីណាវិញយាយដឹងទេ?

ខ៖ នៅយើងនេះហ្នឹង នៅយើងកំពង់សំណាញ់ហ្នឹង!!

ក៖ នៅកំពង់សំណាញ់ដែរ?

ខ៖ តែគ្រាន់តែមានប្ដីនៅខាងតាកែវដែរ!!

ក៖ ហ្ហ៎!!អិចឹងសុទ្ធតែឃើញគ្នាតាមខ្សែ!!

ខ៖ចាំ!!

ក៖ យាយដឹងថាគាត់កើតជំនាន់ណាជំនាន់ណីអីអត់?

ខ៖ អត់ដឹងទេកូន!!អត់ដឹងមិនដឹងគាត់កើតពីកាលណាអត់ដូចថាអត់យកចិត្តទុកដាក់អញ្ចឹងណាស់!!

ក៖ ចាំ!!តែនិយាយទៅម៉ែមិនដែលប្រាប់អីពីយាយព្រោះដោយសារគាត់អត់ទាន់(អត់ចាំមុខ)។

ខ៖ ចាំ គាត់អត់បាននិយាយប្រាប់ផង!!

ក៖ ចុះដល់ពេលតាវិញតាអ៊ុយហេ?

ខ៖ តាអ៊ុយ!!

ក៖ ស្គាល់ត្រកូលតាអ៊ុយទេយាយ?

ខ៖ តាអ៊ុយមិនដឹងត្រកូលអីទេនេះញ៉ុមមិនដឹង ញ៉ុមអត់ស្គាល់ផង។

ក៖ យាយកើត ឃើញមុខតាអ៊ុយទេ?

ខ៖ មិនដែលទេកូន!!

ក៖ ដូចតែយាយដែរហេ?

ខ៖ ចាំ!!មិនដឹងទេដូចអត់ដែលដូចអត់ស្គាល់!!

ក៖ អត់ស្គាល់!!

ខ៖ ព្រោះអីម៉ែញ៉ុមគាត់កំព្រាតាំងពីទូចៗ ឪពុកម្ដាយស្លាប់អស់ទៅពីទូចគាត់នៅជាមួយបងតើ!!

ក៖ចាំ អញ្ចឹងគាតក៏អត់សួរដឹងអីពីឪពុកម្ដាយគាត់ដែរ!!

ខ៖ ចាំ អត់សួរដឹងអីដែរ!!

ក៖ ចាំអានិតគាត់ណាស់អញ្ចឹង!!កំព្រាតាំងពីទូចៗ!!

ខ៖ ដូចថាកេរ្តិ៍អាករណ៍នៅកំពង់សំណាញ់ហ្នឹងច្រើនណាស់ដល់ពេលឪពុកស្លាប់ទៅអត់បានកាត់ឈ្មោះមកលើគាត់មកលើបងប្អូនអី!!គេទាមទារយកអស់ៗ!!

ក៖ហ៊ឺៗ!!

ខ៖ ដែលគេបំបាត់យកអស់ទៅ!!ដល់ពេលនេះម៉ែខ្ញុំហ្នឹងគាត់បានលុយបាកកាក់គាត់ទិញដូចថាទិញកេរ្តិ៍យើងនៅតែដដែលៗហ្នឹង!!

ក៖ចាំ!!

ខ៖ ចាំ!!

ក៖ទិញ?

ខ៖ទិញ!!

ក៖ តាមពិតត្រូវបានលើខ្លួនឯងដោយអត់អស់លុយសោះហ្នឹងហាំ!!តែដល់ពេលបងប្អូនអត់មានចែកអោយក្មួយខ្លះ!!

ខ៖ អត់មានទេ!!

ក៖យ៉ាប់ណាស់ចិត្តអាក្រក់ណាស់!! ឥឡូវយាយ ឥឡូវចូលដល់ជីដូនជីតាខាងឪពុកវិញ!!កើតទាន់តើយាយហេ?ឪពុកខាងតាគឹម អ៊ែលនេះហិ?

ខ៖ តាហ្នឹងតាគឹមហ្នឹងប៉ុន្មានមិនដឹងឪពុកគាត់ស្អីគេគឹមទេ!!ញ៉ុមអត់ស្គាល់ដែរញ៉ុមស្គាល់តែគេហៅតែតាគឹមតាគឹមហ្នឹង!!

ក៖តែអត់ស្គាល់ត្រកូលគាត់ទេ?

ខ៖ ចាំ!!តាគឹមហ្នឹងស្រុកកំនើតគាត់ហ្នឹងនៅខាងកំពតណោះទេ!!

ក៖ ចុះមិញតាអ៊ុយមីញនៅខាងតាកែវ?

ខ៖ នៅខាងតាកែវចាំ!!

ក៖ នៅអាខាងអីគេ អាឃុំ?

ខ៖ ឃុំចំប៉ី!!

ក៖ ឃុំចំប៉ី ស្រុកបាទីហ្នឹង!!

ខ៖ចាំ!!

ក៖ហើយតាគឹម!!!

ខ៖ តាគឹមហ្នឹងគាត់នៅកំពត ប៉ុន្តែពីដើមគាត់ធ្វើថៅហ្វាយស្រុក!!

ក៖ អូវ ធំណាស់យាយ!!

ខ៖
ហើយដល់ពេលគាត់ដើរនៅតាមស្រុកតាភ្លូមិអញ្ចឹងទៅគាត់មកជួបយាយញ៉ុមធ្វើប្រពន្ធចុងទេ!
!

ក៖ហ្ហ៎!!

ខ៖ ប្រពន្ធចុងគាត់!!

ក៖ ហើយបានមានអើរបានមានឪពុករបស់យាយទៅ?

ខ៖ចាំ!!មានឪពុក មាន៣នាក់!!មួយនោះឈ្មោះ បងបង្អស់ឈ្មោះតាអី

ក៖ បងប្អូនតាអ៊ែលហោ?

ខ៖ ចាំបងប្អូនតាអ៊ែល មានបងប្អូន៣នាក់សុទ្ធតែប្រុសៗ!!

ក៖ចាំ!!តែតាគឹមមកយកយាយហោ?

ខ៖ ចាំ!!

ក៖ យាយឈ្មោះអីគេវិញ?

ខ៖ យាយហ្នឹងឈ្មោះយាយហ៊ីង!!

ក៖ យាយហ៊ីងចាំ!!អើរប្ដីគាត់ឈ្មោះតាគឹមហ្នឹង?

ខ៖ចាំ!!

ក៖ យាយកើតទាន់តាគឹមហ្នឹងទេ?

ខ៖ អត់ទាន់ទេកូនឮសូរតែឪពុកញ៉ុមនិយាយ។

ក៖មើលគាត់និយាយអីគេខ្លះមើលយាយនិយាយប្រាប់មើល!!

ខ៖ គាត់ពីដើមគាត់ធ្វើចៅហ្វាយស្រុកអីទៅណាមកណាគេជិះតែសេះទេ!!

ក៖អូ!!

ខ៖ ហើយពាក់អាវករត្រង់ហើយយើងពីដើមយើងមានអាម្ញូកសរហើយម្កុដតិចនោះ!!

ក៖ហ្នឹងហើយ!!

ខ៖ ដូចពីដើមម្ញូកអានៅក្នុងវាំងហ្នឹងអញ្ចឹងណាស់!!

ក៖ ចាំ!!អីគេមានអញ្ចឹងមែនយាយណោះ?

ខ៖ មានហ្នឹងហើយ!!

ក៖ហ្ហូ!!

ខ៖ហើយមានយើងពីដើមឡេវអាវយើងមាន ឥឡូវហ្នឹងគេថាប្លាទីនអីអញ្ចឹងទៅណាស់!!

ក៖ហ៊ីៗ!!

ខ៖
ពីដើរឡេវអាវក្រហមៗគេយកទៅធ្វើក្រវិលទៅធ្វើអីពាក់បានហ្នឹង!!យាយញ៉ុមគាត់ថាយកទៅធ្វើក្រវិលយកទៅធ្វើអីពាក់បានហ្នឹង!!

ក៖ចាំ!!

ខ៖ អត់ខ្មៅទេ!!ហើយម៉េចគាត់ហៅម៉េច!!ទុំវា! ពីដើមគេមិនមែនហៅប្លាទីនដូចយើងទេ គេហៅទុំវា។

ក៖ ទុំវា !!

ខ៖ ហ្នឹងហើយ!!

ក៖ ដឹងអ្នកណាគេដូរមកដាក់ប្លាទីនវិញ!!ចុះមិញសំរាប់យាយវិញឈ្មោះអីគេលោកយាយ?

ខ៖ យាយហ៊ុង។

ក៖ យាយហ៊ុង?

ខ៖ចាំ!!

ក៖ ហើយអើរកើតមកឃើញយាយហ៊ុងទេយាយ?

ខ៖ មិនបានជួបគាត់ដែរទេកូន!

ក៖អ៊ីចឹងតាយាយទាំងសងខាងយាយអត់បានជួបម៉ងយាយណោះ?

ខ៖ ចាំអត់បានជួបផង!!

ក៖ហ៊ឺ!! តែឥឡូវយាយម៉េចដែរ ឪមានដែលប្រាប់ថាយាយម៉េចអត់?

ខ៖ អត់មានប្រាប់អីផង ព្រោះអីយាយហ្នឹងគាត់ដូចថាឪពុកញ៉ុមការជាមួយម៉ែញ៉ុមហើយទៅក៏គាត់បែកផ្ទះទៅ ហើយយាយញ៉ុមក៏គាត់នៅជាមួយកូនបង នៅជាមួយតាមើមនៅជាមួយអីអញ្ចឹងទៅ!! បងបង្អស់ឈ្មោះមើម !គឺម មើម ហើយទី២ហ្នឹង គឺម យិន។

ក៖ អ៊ីចឹងតាអ៊ែលហ្នឹងពៅគេទេអញ្ចឹង។

ខ៖ចាំ!

ក៖ហ្ហ៎!!ខ៖ ក៏បែកគ្នារហូតទៅ!!

កៈ ឥឡូវពួកគាត់ និយាយទៅបងប្អូនតាអ៊ែលគាត់នៅរស់អីវ៉ាន់ដែរតើយាយហេ?

ខៈ ស្លាប់អស់ហើយកូន!!

កៈ តែបើគាត់នៅក៏គាត់ចាស់ៗដែរ?

ខៈ ចាំ ចាស់ៗ។

កៈ ខ្ទង់១០០អីអស់ហើយហ្នឹងហេ?

ខៈចាំ!!កាលគាត់ស្លាប់៧២គាត់ស្លាប់យូរដែរហើយ!!

កៈ ហ្នំអញ្ចឹងគាត់រៀងច្រៃៗដែរហើយហ្នឹងហេ?

ខៈ ហ្នឹងហើយ!!

កៈ ចាំ!!អញ្ចឹងលោកយាយមានចងចាំពីបងប្អូនដូនតាកូនចៅអីទៀតទេ?

ខៈ អត់មានអីចាំទេកូន។

កៈ
លោកយាយសំរាប់បងប្អូនទាំងអស់ហាំមានដែលអ្នកណាគេធ្លាប់ទៅរស់នៅប្រទេសខាងក្រៅអីគេទេ?

ខៈ អត់ទេកូនញ៉ុមមានតែម្នាក់ឯងអត់មានអ្នកណាគេទៅនៅទេ។

កៈ ដូចរបៀបថាជីដូនមួយឬក៏អីវ៉ាន់ឬក៏អ្នកណាគេអីវ៉ាន់ផ្សេង?

ខៈ អត់។

កៈ
ចាំហ្នឹងហើយ!!អ៊ីចឹងអរគុណលោកយាយដែលបានអោយញ៉ុមបានសំភាសន៍ប្រវត្តិអំពីបងប្អូនដូនតា
អញ្ចឹងអ្វីទាំងអស់កូនចៅលោកយាយគាត់នឹងបានស្តាប់ហើយនឹងដឹងអំពីជីវប្រវត្តិរបស់ពួកគាត់ចាំ។